# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១២៥៧.កយ.ព្រទ-២០០៥

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

លោកប្រធានតុលាការខេត្ត-ក្រុង

លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង

**កម្មវត្ថុ:** ស្តីពីបញ្ហានៃការថតចម្លងស៊ីឌី និងវីស៊ីឌីក្លែងក្លាយរបស់ផលិតកម្ម និងសិល្បករសិល្បការីនី។

**យោង:** លិខិតៈលេខ ៩៦២ សជណ ចុះថ្ងៃទី១៧-០៦-២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

តតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធាន និងលោកព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត-ក្រុងជ្រាបថា ទីស្តីការគណៈរដ្ឋមន្ត្រីបានស្នើសុំក្រសួងយុត្តិធម៌ជួយជំរុញតុលាការខេត្ត-ក្រុង ឱ្យយកចិត្តទុកដាក់ប្រឹងប្រែងឱ្យអស់លទ្ធភាពជំនុំជម្រះសំណុំរឿងដែលពាក់ពន្ធ័នឹងការលួចថតចម្លងសិទ្ធិអ្នកនិពន្ធ ទាំងសំណុំរឿងចាស់ទាំងសំណុំរឿងថ្មីឱ្យបានឆាប់រហ័សធ្វើការផ្តន្ទាទោសជនល្មើសក្នុងគោលដៅការពារ និងលើកតម្កើងវិស័យសិល្បៈជាពិសេសធានាចំពោះការធ្វើពាណិជ្ជកម្មនៅក្នុងនិងក្រៅប្រទេស ។

សេចក្តីនេះ ក្រសួងយុត្តិធម៌សូមលោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត-ក្រុងទាំងអស់ បើសិនជាមានសំណុំរឿងក្តីលួចថតចម្លងសិទ្ធិអ្នកនិពន្ធត្រូវលើកយកមកចាត់ការតាមនីតិវិធីដាក់ជំនុំជម្រះឱ្យបានឆាប់រហ័ស តាមគោលនយោបាយលើកស្ទួយវិស័យសិល្បៈរបស់រដ្ឋាភិបាល ។

សូមលោកប្រធាន និងលោកព្រះរាជអាជ្ញាទទួលនូវសេចក្តីរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៥

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ដើម្បីជូនជ្រាបជាព័ត៌មាន
- ឯកសារ-កាលប្បវត្តិ